D138/1/6

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៨)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៧ មេសា ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / APR / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

---

សាធារណៈ:

## សេចក្តីបង្គាប់ដល់សហមេធាវីរបស់លោក អៀង សារី ទាក់ទងនឹង “សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ”

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / APR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញមាន "សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា ចំពោះ "បណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ" ("សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា") ដែលបានដាក់នៅថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៩។

១. សហព្រះរាជអាជ្ញា លើកឡើងនូវការសង្កេតបឋមដូចតទៅ:

ក. "អង្គបុរេជំនុំជម្រះ អាចពិចារណាដោយច្រានចោលបណ្តឹងឧទ្ធរណ៍នេះ ដោយសារតែខ្វះខាតខាងសិទ្ធិប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី។ [...] ទោះបី ដើមបណ្តឹងឧទ្ធរណ៍មានសិទ្ធិប្តឹង និងសំអាងនៃបណ្តឹងក៏ដោយ បណ្តឹងឧទ្ធរណ៍នេះក៏មិនត្រូវបានអនុញ្ញាតដែរ យោងតាមវិធាន៧៤(៣) ដែលបានរៀបរាប់គ្មានសល់ពីប្រភេទនៃបណ្តឹងឧទ្ធរណ៍ដែលជនត្រូវចោទ អាចនាំមកនៅចំពោះមុខអង្គបុរេជំនុំជម្រះ"[១]។

ខ. "បញ្ហានៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលយុត្តិធម៌ ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការប្រមាថមាននៅក្នុងយុត្តាធិការជាតិ និងអន្តរជាតិមួយចំនួន គឺជាបញ្ហាច្រើនតែមានរវាងតុលាការ និងជនល្មើសដែលបានចោទប្រកាន់។ ហេតុដូចនេះ សហព្រះរាជអាជ្ញាមិនពិចារណាខ្លួនឯងថា ជាគូភាគីពេញលេញចំពោះដំណើរការនីតិវិធីទាំងនេះទេ ប៉ុន្តែគ្រាន់តែជា "ភាគីដែលចាប់អារម្មណ៍" ជាមន្ត្រីនៃតុលាការនេះ"[២]។

គ. "សិទ្ធិទទួលបានការជំនុំជម្រះ មិនចាំបាច់មានន័យថា ទាល់តែមានសវនាការផ្ទាល់មាត់ទេ វាអាចដាក់បញ្ចូលនូវការសម្រេចមួយដែលមានសំអាងហេតុ និងជាសាធារណៈ នៅលើសេចក្តីថ្លែងសំអាងជាលាយល័ក្ខអក្សរមួយក៏បាន។ [...] ខណៈបញ្ហានៅក្នុងបណ្តឹងឧទ្ធរណ៍នេះជាបញ្ហាសំខាន់ ការសម្រេចបញ្ចប់លើបណ្តឹងឧទ្ធរណ៍អំពីសេចក្តីថ្លែងសំអាងជាលាយល័ក្ខអក្សរតែមួយមុខ មិនអាចថាជាសាធារណៈតិចតួចជាង ឬមានតម្លាភាពតិចតួចឡើយ ប្រសិនបើការដាក់ឯកសារ និងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវបានគេដាក់ឲ្យរកបាននៅលើកម្មសិទ្ធជាសាធារណៈរួចទៅហើយនោះ។ [...]

[១] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានលើការសម្ងាត់នៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០៩, ឯកសារលេខ D138/1/5 វាក្យខណ្ឌ ៣, ៦ និង ៧ (សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា)

[២] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា, វាក្យខណ្ឌ៥។

តុលាការអន្តរជាតិ ដែលធ្វើការកាត់សេចក្តីលើបទឧក្រិដ្ឋដែលមានទំហំ និងភាពស្មុគស្មាញស្រដៀងគ្នានឹងតុលាការនេះដែរតែងតែធ្វើការសម្រេចយ៉ាងទៀងទាត់លើបណ្តឹងឧទ្ធរណ៍ អំពីសេចក្តីថ្លែងសំអាងជាលាយលក្ខអក្សរតែមួយមុខគត់។ ជាការពិតណាស់តុលាការទាំងនេះ ក៏បានច្រានចោលពាក្យសុំឱ្យមានសវនាការផ្ទាល់មាត់ ដោយផ្អែកទៅលើតែទឡ្ហីករណ៍នៃ "ភាពស្មុគស្មាញនៃបញ្ហា" តែមួយមុខប៉ុណ្ណោះ"[៣]។

២. នៅក្នុងបរិបទនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីគ្មានអ្នកតំណាង [សេង ចាន់ធារី] បានដាក់សេចក្តីថ្លែងការណ៍របស់ពួកគេលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ[៤]។

៣. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្នើថា "ការពិភាក្សាអំពីឥម្លាភាពនៃតុលាការ គឺមានលក្ខណៈចាំបាច់ និងសំខាន់ណាស់ និងដីការបស់ ក.ស.ច.ស បានប៉ះពាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីរបស់ពួកគាត់ផងដែរ"[៥]។

៤. ភាគីដើមបណ្តឹងរដ្ឋប្បវេណីគ្មានអ្នកតំណាង [សេង ចាន់ធារី] ស្នើសុំដល់អង្គបុរេជំនុំជម្រះ "សិទ្ធិក្នុងការប្រាស្រ័យដោយផ្ទាល់ នៅក្នុងពេលសវនាការអង្គបុរេជំនុំជម្រះ នាពេលសវនាការខាងមុខនេះ [...] លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ"[៦]។

៥. ដោយពិចារណាលើបញ្ហាដែលបានលើកឡើង អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការចាំបាច់ ដើម្បីសួរយោបល់ពីសហមេធាវីការពារក្តី លោក អៀង សារី លើសេចក្តីសង្កេតបឋមរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

---

[៣] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា, វាក្យខណ្ឌ ១០ និង១១។

[៤] សេចក្តីថ្លែងការណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង[សេង ចាន់ធារី] ស្តីពីបណ្តឹងឧទ្ធរណ៍អៀង សារី ប្រឆាំងនឹងដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៩, ឯកសារលេខ D138/1/4 និងសេចក្តីថ្លែងការណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៩ ឯកសារលេខ D138/1/3។

[៥] សេចក្តីថ្លែងការណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៩ ឯកសារលេខ D138/1/3 វាក្យខណ្ឌ៥។

[៦] សេចក្តីថ្លែងការណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង[សេង ចាន់ធារី] ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៩ ឯកសារលេខ D138/1/4 វាក្យខណ្ឌ ៣។

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះបង្គាប់:

អនុញ្ញាតឱ្យសហមេធាវីការពារក្តីរបស់ លោក អៀង សារី ផ្តល់ការបញ្ជាក់ និង/ឬ សំដែងយោបល់ក្នុងរយៈពេល ១៤ថ្ងៃ គិតចាប់ពីទទួលបានសេចក្តីណែនាំនេះ ទាក់ទងនឹងបញ្ហាដូចខាងក្រោម:

១. បញ្ជាក់ថា អ្នកណាគួរត្រូវបានចាត់ទុកជាភាគីដាក់ឯកសារក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ។

២. បញ្ចេញយោបល់របស់ខ្លួន លើសេចក្តីសង្កេតបឋមរបស់សហព្រះរាជអាជ្ញា ដែលបានដកស្រង់ខាងលើ។

៣. បញ្ចេញយោបល់របស់ខ្លួន លើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដកស្រង់ខាងលើ។ ៕

ភ្នំពេញ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

ប្រាក់ គឹមសាន